១៧

100/7

តុលាការកំពូល

## ក្នុងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១០៩
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២

សាលដីកា
លេខ: ១២០
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទីបី ខែឧសភា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៥៨ក្រ.VI "ញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១០៩ ចុះថ្ងៃ២៨ ខែមិថុនា ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទៈ មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៦។បទល្មើសព្រហ្មទណ្ឌដែល មានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

១-ជនជាប់ចោទឈ្មោះ [redacted] ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស ជាតិខ្មែរ អាយុ២១ឆ្នាំ កើតនិងទីលំនៅភូមិ ទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ របររកស៊ីកម្មករសំណង់ ឪពុកឈ្មោះ [redacted]" ម្តាយឈ្មោះ [redacted]" នៅលើរ ទោសពីមុនគ្មាន កំរិតវប្បធម៌ថ្នាក់ទី៥ថ្មី។ ឃុំខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

-មានមេធាវីការពារលោក [redacted]



Scanned by CamScanner

100/6

២-ជនជាប់ចោទឈ្មោ[redacted]ភេទប្រុស ជាតិខ្មែរ អាយុ២៩ឆ្នាំ កើតនៅភូមិទួលតាឯក ឃុំស្វាយប៉ោ១ ស្រុកទិរ្វមខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្ននៅភូមិអូរតាគាំ២ ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ របររកស៊ីកម្មករ ឪពុកឈ្មោ[redacted] "រ" ម្តាយឈ្មោះ[redacted]" នៅលីវ។ (គេចខ្លួន) មានដីកាចាប់ខ្លួនចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨។

៣-ជនជាប់ចោទឈ្មោះ[redacted]ប្រុស អាយុ៣១ឆ្នាំ កើតនៅភូមិទួលតាឯក ឃុំស្វាយប៉ោ១ ស្រុកទិរ្វមខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្នភូមិអូតាគាំ២ ឃុំទួលតាឯក ស្រុក-ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ របររកស៊ីកម្មករ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោ[redacted] នៅលីវ (គេចខ្លួន) មានដីកាចាប់ខ្លួនចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨។

៤-ជនជាប់ចោទឈ្មោះ[redacted]ហៅ [redacted]ភេទប្រុស អាយុ១៨ឆ្នាំ កើតនៅភូមិកំពង់ក្របី ឃុំឯកភាព ទិរ្វមខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្នភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង សាសនាព្រះពុទ្ធ របររកស៊ីមិនពិតប្រាកដ ឪពុកឈ្មោះ[redacted] ម្តាយឈ្មោះ រី [redacted]នៅលីវ។ (គេចខ្លួន) មានដីកាចាប់ខ្លួនចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៨។ចាប់ និងឃុំខ្លួនថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៨។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ក្នុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិព្រៃទទឹង ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

-កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ វេលាម៉ោង១១យប់ ជនល្មើសឈ្មោះ [redacted] ភេទប្រុស ដែលមានទីលំនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង និងបក្សពួក បាននាំគ្នាពួនស្ទាក់ចាំកាក់ម៉ូតូរបស់ជនរងគ្រោះ ពេលឃើញម៉ូតូរបស់ជនរងគ្រោះជិះ កាត់វិបតាមផ្លូវរថភ្លើងមកខាងត្បូងបានចម្ងាយប្រហែលជា២០០ម ជនល្មើសរូបនេះបានចេញមកកាក់ពីមុខម៉ូតូ ហើយបញ្ជាឱ្យឈប់ បន្ទាប់មកទៀតបក្សពួករបស់ជនល្មើសបានលូកហោប៉ៅ របស់ជនរងគ្រោះ [redacted]យកប្រាក់អស់ចំនួន១០.០០០រៀល ចំណែកជនរងគ្រោះ[redacted]ានរត់ចេញពីម៉ូតូចម្ងាយប្រហែលប្រាំម៉ែត្រ តែត្រូវជនល្មើសស្ទាក់ជាប់ ហើយទាមទារយកទូរស័ព្ទដៃ ប៉ុន្តែជនរងគ្រោះនេះមិនព្រមឱ្យ ជនល្មើសក៏កាប់ និងចាក់ទៅលើជនរងគ្រោះបណ្តាលឱ្យស្លាប់នៅនឹងកន្លែងតែម្តង។ បន្ទាប់ពីធ្វើសកម្មភាពទៅលើជនរងគ្រោះហើយ ជនល្មើសក៏នាំគ្នារត់គេចខ្លួនអស់ទៅ។

តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨ របស់ឈ្មោះ [redacted]ក្នុងពីមនុស្សឃាតដោយចេតនា ដោយសំអាងហេតុថា កាលពីថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០៨ ម៉ោង០១ និង០០នាទី ខ្លួនបានទទួលដំណឹងពីឈ្មោ[redacted]ភេទប្រុស ប្រាប់ថាឈ្មោះ[redacted]ភេទប្រុស ត្រូវរបួសធ្ងន់ប្រហែលស្លាប់ហើយ និងឈ្មោ[redacted]ភេទប្រុស អាយុ២៧ឆ្នាំ ត្រូវរបួសនៅត្រង់ចំណុចស្ថានីយ៍រថភ្លើងខេត្តបាត់ដំបង។ ពេលនោះខ្លួនមកដល់កន្លែងកើតហេតុនៅវេលាម៉ោង២ និង៣០នាទី



Scanned by CamScanner

ឃើញឈ្មោ[redacted]កស្លាប់នៅខាងជើងផ្លូវរថភ្លើងហើយបាត់ទូរស័ព្ទដៃម៉ាកសាំសុងលេខ ០១២ ១៩៤ ៦១០៥ និងប្រាក់មួយចំនួន។សំណូមពរសុំឱ្យសមត្ថកិច្ចជួយស្រាវជ្រាវរកសំភារៈឱ្យ ខ្លួនវិញ ចំណែកជនល្មើសសុំឱ្យសមត្ថកិច្ចផ្តន្ទាទោសទៅតាមច្បាប់

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបងថាៈ មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ[redacted]ប្រុស អាយុ២១ឆ្នាំ (មានសាវតា), ឈ្មោះ[redacted]ទប្រុស អាយុ២៩ឆ្នាំ(មានសាវតា), ឈ្មោ[redacted]ទប្រុស អាយុ៣១ឆ្នាំ(មានសាវតា), ឈ្មោះ[redacted]ហៅ[redacted]ភេទប្រុស អាយុ១៨ឆ្នាំ(មានសាវតា)[redacted]ភេទប្រុស(គ្មានសាវតា) ពីបទៈ "ឃាតកម្មគិតទុកជាមុន" ប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០១០២/០០៤ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២។ តែក្រោយការប្រព្រឹត្តឈ្មោ[redacted]ស បានគេចខ្លួន គ្មានសាវតាគ្រប់គ្រាន់ធ្វើ គប្បីធ្វើការលើកលែងចោទ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ២៣"ឃ" ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលបានសម្រេចៈ

១-ផ្តន្ទាទោសៈ

ក.ឈ្មោ[redacted]ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់១៥ឆ្នាំ (ដប់ប្រាំឆ្នាំ) តម្រូវឱ្យធ្វើការងារដោយគិតចាប់ពីថ្ងៃចាប់ខ្លួនថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

ខ.ឈ្មោះ[redacted] ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ

គ.ឈ្មោះ[redacted]ភេទប្រុស អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ

ឃ.ឈ្មោះ[redacted]ហៅ[redacted]ទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារ តម្រូវឱ្យធ្វើការងារក្នុងម្នាក់ៗ១៥ឆ្នាំ(ដប់ប្រាំគត់)គិតចាប់ពីថ្ងៃចាប់ខ្លួនបានពីបទៈ មនុស្សឃាតគិតទុក ជាមុន ប្រព្រឹត្តនៅភូមិទួលតាឯក ឃុំទួលតាឯក ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៨ បទល្មើស ព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ[redacted]និងដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោ[redacted]សិទ្ធិប្តឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៤១ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោ[redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៣"ឃ" ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង គ្រប់ចំណុចនៃសេចក្តីសម្រេចទាំងមូល។



Scanned by CamScanner

100/៤

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា:សាលក្រមព្រហ្មទណ្ឌលេខ ២៣"ឃ" ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់សាលាដំបូងខេត្តបាត់ដំបង បានសំរេចមានលក្ខណៈ ត្រឹមត្រូវតាមអង្គហេតុ និងគតិច្បាប់ហើយ។ គប្បីតំកល់សាលក្រមព្រហ្មទណ្ឌនេះទុកជាបានការ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៣៨"ញ" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់-តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៣"ឃ" ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ របស់ សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោ[redacted]

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ កំបាំងមុខជនជាប់ចោទ និងដើមបណ្ដឹង ទុកសិទ្ធិឲ្យប្ដឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងទាស់លេខ៧២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៥៨ក្រVI"ញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្ដឹងទាស់ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោ[redacted] ជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៣៨"ញ" ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១០ របស់ឧទ្ធរណ៍ ទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ។ បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ១៥២ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៥៨ក្រVI"ញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

-បានឃើញសារណាការពារចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់។



Scanned by CamScanner

100/3

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថា:

១-ទទួលបណ្ដឹងសាទុក្ខលេខ១៥២ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់ ឈ្មោះ [redacted]កជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់គតិ ច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៥៨ក្រVI"ញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្ដាប់សាវតាជាតិ និង ចម្លើយអះអាងរបស់ជនត្រូវចោទឈ្មោះ[redacted]ពេលសវនាការថា: នៅពេលកើតហេតុ ខ្លួនមិនមានវត្តមាននៅជាមួយឈ្មោះ[redacted] [redacted]ខ្លួននៅមើលកុននៅផ្ទ[redacted]ប៉ុន្តែមុនពេលកើតហេតុប្រហែលម៉ោង ៨ យប់ ខ្លួនពិតជាបានឈរនិយាយលេងជាមួយឈ្មោះ[redacted] នៅក្រោមដើមទឹកដោះគោមែន តែខ្លួនមិនបានចូលរួមធ្វើសកម្មភាពជាមួយឈ្[redacted] ព្រោះថាខ្លួនត្រូវបានឈ្មោ[redacted]ខ្លួនឲ្យមកដេកនៅផ្ទះមុនពេលកើតហេតុ។

សំណូមពរ: សុំឲ្យតុលាការលើកលែងចោទប្រកាន់ ព្រោះខ្លួនជាប់ពន្ធនាគារមានរយៈពេល ០៥ឆ្នាំហើយ។

-បានស្ដាប់សាវតាជាតិ និង ចម្លើយអះអាងរបស់ឈ្មោះ [redacted]ពេលសវនាការថា: ពេលកើតហេតុឈ្មោ[redacted]ន ចូលរួមក្នុងការប្រព្រឹត្តបទល្មើសនេះទេ គឺមានតែរូបខ្លួន, ឈ្មោ[redacted]ន្តែពីក្បាលល្ងាចឈ្មោះ[redacted]បានឈរលេងជាមួយ និង ពួកខ្លួនពិតមែន ឯអាវុធដែលពួកខ្លួនប្រើប្រាស់វិញ គឺកាំបិតហាន់ដើមចេករបស់ជីតាខ្លួន មិនមែនជាអាវុធជាវសាមូរ៉ៃទេ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់លេ[redacted]ធាវីការពារឲ្យជនជាប់ចោទនាពេលសវនាការថា: ឈ្មោ[redacted]ារភាពថាខ្លួនជាអ្នកសម្លាប់ជនរងគ្រោះដោយផ្ទាល់ដៃដោយកាំបិតហាន់ដើមចេក មិនពាក់ព័ន្ធជាមួយនឹងកូនក្ដីរបស់ខ្លួនពេ[redacted] ឯសាលាដំបូងខេត្តបាត់ដំបងវិញ មិនបានហៅសាក្សីកូនក្ដីរបស់ខ្លួនមកបំភ្លឺទេ ដូចជាមានឈ្មោះ[redacted] [redacted]ការមិនសួរចម្លើយសាក្សីផ្ទុយទៅនឹងមាត្រា១៥៣, ១៥៨, ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

-នៅសាលាឧទ្ធរណ៍តំណាងមហាអយ្យការបានសុំឲ្យក្រុមប្រឹក្សាសម្រេចលើកពេលនៅថ្ងៃក្រោយដើម្បីកោះហៅសាក្សី និងឈ្មោ[redacted]លចាប់បានកាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩ មកសួរយកចម្លើយតែសាលាឧទ្ធរណ៍មិនបានលើកពេលទេ។

Scanned by CamScanner

សំណូមពរៈ សុំក្រុមប្រឹក្សាជំនុំជម្រះ សម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងសម្រេច ឱ្យកូនក្តីខ្លួន រួចផុតពីបទចោទប្រកាន់តាមមាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថាៈ ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងមេធាវីរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១៥២ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់ជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជម្រះ បានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ តម្កល់សេចក្តីសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបង ដែលផ្តន្ទាទោសឈ្មោះ[redacted]ាក់ពន្ធនាគារចំនួន១៥ឆ្នាំ ដោយជឿថាឈ្មោ[redacted] ប្រព្រឹត្តអំពើមនុស្សឃាតគិតទុកជាមុន នោះជាការភ័ន្តច្រឡំពីព្រោះ៖

+នាសវនាការរបស់តុលាការកំពូល ក៏ដូចជាគ្រប់ដំណាក់កាលនីតិវិធីនៃរឿងក្តីនេះ ដែរឈ្មោះ[redacted]តឆ្លើយបដិសេធ ថានៅពេលកើតហេតុ ខ្លួនមិនមានវត្តមាននៅជាមួយ ឈ្មោះ[redacted] គឺខ្លួននៅមើលកុននៅ[redacted] ក៏ប៉ុន្តែមុនពេលកើតហេតុ ប្រហែលម៉ោង៨យប់ ខ្លួនពិតជាបានឈរនិយាយលេង ជាមួយ ឈ្មោះ[redacted]នៅក្រោមដើមទឹកដោះគោមែន ដែលតុលាការកំពូលពិនិត្យឃើញថា អង្គហេតុនេះស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹង ចម្លើយរបស់ឈ្មោ[redacted]ជនរងគ្រោះម្នាក់ដែល ជិះម៉ូតូជាមួយឈ[redacted]គ្រោះម្នាក់ទៀត ដែលត្រូវបាត់បង់ជីវិតក្នុងហេតុការណ៍នេះដែល ឆ្លើយថាមនុស្ស០៣នាក់ ស្ទាក់ផ្លូវខ្លួន ប៉ុន្តែខ្លួនមិនស្គាល់អ្នកទាំង០៣នាក់ទេ គ្រាន់តែឃើញមានល្បិត តួចៗទាំង០៣នាក់។ ក្រៅពីនេះឈ្មោ[redacted]ទណ្ឌិតម្នាក់ដែរបានឆ្លើយអះអាងថា ពេលកើតហេតុ នេះឈ្មោ[redacted]នបានចូលរួមក្នុងការប្រព្រឹត្តបទល្មើសនេះទេ គឺមានតែរូបខ្លួនឈ្មោ[redacted] និងឈ្មោះ[redacted]ព្តក្បាលល្វាចឈ្មោ[redacted]នឈរលេងជាមួយពួកខ្លួនពិតមែន ឯអាវុធ ដែលពួកខ្លួនប្រើប្រាស់វិញ គឺជាកាំបិតហាន់ដើមចេករបស់ជីតាខ្លួន មិនមែនជាដាវសាមូរ៉ៃទេ។ មាន សាក្សីម្នាក់ទៀតឈ្មោ[redacted]នឃើញហេតុការណ៍នេះដែរថា មិនអាចមើលឃើញ ច្បាស់ទេ គឺមើលឃើញខ្លះដោយពន្លឺភ្លើងម៉ូតូ ប៉ុន្តែខ្លួនស្គាល់ឈ្មោ[redacted]ាស់។



Scanned by CamScanner

១៨

100/1

ចំណុចនេះតុលាការកំពូលអាចសន្និដ្ឋានបានថា វេលាយប់ម៉ោង១០ជាង បើមានតែភ្លើងម៉ូតូ ដែលបើកកាត់ម្តងម្កាល នោះពិតជាមិនអាចសម្គាល់ថាជនណាខ្លះជាអ្នកប្រព្រឹត្តបទល្មើសនេះទេ ដូចនេះចម្លើយរបស់ឈ្មោះ[redacted]ដែលថាបានឃើញឈ្មោះ[redacted]ជាមួយអ្នកពីរនាក់ទៀត នៅពេលកើតបទល្មើស នោះគឺអាចជាការមិនទាន់ច្បាស់លាស់ទេ។

+ម្យ៉ាងទៀតតុលាការអង្គសេចក្តី ក៏នៅមិនទាន់បានសួរចម្លើយឈ្មោះ[redacted]ស្វែរកឱ្យឃើញថាតើឈ្មោះ[redacted]កំពុងមើលកុនជាមួយអ្នកទាំង០៣ពិតមែននៅឡើយ។

-យល់ឃើញថា: សាលដីកាព្រហ្មទណ្ឌលេខ៥៨ "ក្រVIញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវនឹងគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ១៥២ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់ជនជាប់ចោទឈ្មោះ[redacted]

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៥៨ក្រVI"ញ" ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បន្តការឃុំខ្លួនឈ្មោះ[redacted]ទៅទៀត។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ១០៩ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មី។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៣ ខែឧសភា និងប្រកាសសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញ[redacted]ត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី 05 ខែឧសភា ឆ្នាំ២០១៣

ប្រធានតុលាការកំពូល

ប្រធាន

[redacted]



Scanned by CamScanner